រក្សាសិទ្ធិ © ពត៌មាន :
© ២00១ Project WorldReach © ២00១ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

013KH01A-01

របៀបអធិស្ឋាន



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

១៣

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

ទូលសូមអោយព្រះជាម្ចាស់ជួយអោយអ្នក និងក្រុមរបស់អ្នកកាន់តែចេះអធិស្ឋានថែមទៀត តាមរយៈការសិក្សានេះ ។

ការអធិស្ឋាន គឺជាឯកសិទ្ធិ និង កិត្តិយស

ដោយសារតែព្រះគ្រីស្តបូជាព្រះជន្ម ទើបយើងបានចូលទៅដល់បល្ល័ង្ក គឺវត្តមានរបស់ព្រះជាម្ចាស់ដ៏ធំខ្ពស់បំផុត ។



ក្រោយពេលដែលលោកអដាំ និងនាងអេវ៉ាបានធ្វើបាបហើយ ព្រះជាម្ចាស់បានដាក់ទេវទូតឱ្យយាមវត្តមានដ៏វិសុទ្ធរបស់ព្រះអង្គ ដើម្បីកុំអោយមនុស្សបាបអាចចូលទៅជិតបាន ។

(កំណើតពិភពលោក ៣:២៤)

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋានរាល់ថ្ងៃក្នុងរយៈពេលយូរ (ម៉ាថាយ ២៦:៤០) តាមគំរូសេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់យេស៊ូគ្រីស្ត ដែលនៅក្នុងម៉ាថាយ ៦:៩-១៣ ។
- បង្រៀនគ្រីស្តជនរបស់ក្រុមជំនុំអ្នកអោយចេះអធិស្ឋានរាល់ថ្ងៃស្របទៅតាមគំរូនៃសេចក្តីអធិស្ឋាន នៅក្នុងម៉ាថាយ ៦:៩-១៣ ។ អធិស្ឋានជាមួយពួកគេ ដើម្បីជួយអោយពួកគេអាចចាប់ផ្តើមអធិស្ឋាន ។ (បើមាននរណាម្នាក់មិនចេះអធិស្ឋានទេ គេអាចថាតាមអ្នកបាន) ។
- ទន្ទេញ យ៉ូហាន ១៦:២៤ : *«មកទល់ពេលនេះ អ្នករាល់គ្នាពុំទាន់បានទូលសូមអ្វីក្នុងនាមខ្ញុំទេ ចូរទូលសូមទៅ អ្នករាល់គ្នានឹងបានទទួល ហើយអ្នករាល់គ្នានឹងមានអំណរពេញលក្ខណៈ»* ។
- សូមប្រាប់បងប្អូនរួមជំនឿ ពីចំលើយរបស់ព្រះជាម្ចាស់ចំពោះការអធិស្ឋាន ដើម្បីលើកទឹកចិត្តគេ ដែលគេបានទូលអង្វរសំរាប់អ្នក ។

© Project WorldReach © SEAN

ក្នុងរយៈពេលប្រាំមួយខែទៀត សូមអានបញ្ជីនេះឡើងវិញ ។ អ្នកនឹងភ្ញាក់ផ្អើល ហើយសប្បាយរីករាយ ដោយឃើញពីរបៀបដែលព្រះជាម្ចាស់បានឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់អ្នក ។

អំពើបាបប្រៀបដូចជារបាំងមួយដ៏ធំ ដែលបំបែកមនុស្សចេញពីព្រះជាម្ចាស់ដ៏វិសុទ្ធបំផុត ។ បើគ្មានអ្នកសម្រុះសម្រួលទេ ការអធិស្ឋានរបស់យើងមិនអាចឆ្លងកាត់របាំង ដែលជាអំពើបាបនេះបានទេ ។ (អេសាយ ៥៩:២)



ប៉ុន្តែ ព្រះយេស៊ូគ្រីស្តបើកផ្លូវអោយយើង ដោយសុគត និងមាន
ព្រះជន្មរស់ឡើងវិញ ។



យើងចូលទៅជិតស្តេចលើអស់ទាំងស្តេច ដោយការអធិស្ឋាន ។
ព្រះយេស៊ូគ្រីស្តបានលប់បំបាត់ទោសកំហុស និងអំពើបាបរបស់
យើង ដូច្នេះយើងអាចចូលទៅជិតព្រះបិតាតាមរយៈព្រះអង្គបាន។

៤- តើពេលអធិស្ឋាន អ្នកសរសើរតម្កើងព្រះជាម្ចាស់ដែរឬទេ ?

☐ សរសើរតម្កើង ។

☐ មិនបានសរសើរតម្កើងទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

៥- តើអ្នកអរព្រះគុណព្រះជាម្ចាស់ចំពោះម្ហូបអាហាររបស់អ្នក
និងព្រះពរផ្សេងទៀតដែរឬទេ ?

☐ អរព្រះគុណព្រះជាម្ចាស់ ។

☐ មិនបានអរព្រះគុណព្រះជាម្ចាស់ទេ ប៉ុន្តែ ខ្ញុំនឹងចាប់
ផ្តើម ។

សូមសរសេរពីសេចក្តីដែលអ្នកទូលសូមព្រះអង្គ សំរាប់រយៈពេល
នេះ ។

© Project WorldReach © SEAN

ការប្រឡង (សំនួរសង្ខេបមេរៀន)

១- តើអ្នកអធិស្ឋានក្នុងព្រះនាមព្រះអម្ចាស់យេស៊ូគ្រីស្តរាល់ថ្ងៃដែរឬទេ ?

☐ អធិស្ឋាន ។

☐ មិនបានអធិស្ឋានទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។ ខ្ញុំនឹងសូមអោយព្រះជាម្ចាស់ដាក់បំណងចង់អធិស្ឋាននៅក្នុងចិត្តរបស់ខ្ញុំ ។

២- តើអ្នកអធិស្ឋានអោយអ្នកដែលគ្រប់គ្រងប្រទេសរបស់អ្នកដែរឬទេ ?

☐ អធិស្ឋាន ។

☐ មិនបានអធិស្ឋានទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

៣- តើអ្នកអធិស្ឋានអោយអ្នកដែលមិនទាន់ជឿដែរឬទេ ?

☐ អធិស្ឋាន ។

☐ មិនបានអធិស្ឋានទេ ប៉ុន្តែ ខ្ញុំនឹងចាប់ផ្តើម ។

ព្រះគម្ពីរចែងថា÷...*«ហេតុនេះបងប្អូនអើយ យើងមានចិត្តរឹងប៉ឹងចូលមកក្នុងទីសក្ការៈ ដោយសារព្រះលោហិតរបស់ព្រះយេស៊ូ ព្រោះព្រះអង្គបានបើកមាគ៌ាមួយថ្មី ជាមាគ៌ាដែលមានជីវិត... យើងត្រូវនាំគ្នាចូលទៅជិតព្រះអង្គ ដោយចិត្តទៀងត្រង់...»* ។

(ហេប្រឺ ១0:១៩-២២)

ហេតុនេះហើយ បានជាយើងអធិស្ឋានក្នុងព្រះនាមព្រះយេស៊ូគ្រីស្ត ។

«ដ្បិតមានព្រះជាម្ចាស់តែមួយ មានស្ពានមេត្រីតែមួយរវាងព្រះ-ជាម្ចាស់ និងមនុស្សលោក គឺព្រះគ្រីស្តយេស៊ូដែលជាមនុស្ស ។ ព្រះអង្គបានបូជាព្រះជន្ម ដើម្បីលោះមនុស្សទាំងអស់...» ។

(១ ធីម៉ូថេ ២:៥-៦)

តើអ្វីដែលបង្អាក់មនុស្សធម្មតា មិនឱ្យចូលទៅជិតព្រះជាម្ចាស់ ?

តើនរណាដែលជាអ្នកសម្រុះសម្រួល គឺស្ពានមេត្រីតែមួយរវាង ព្រះជាម្ចាស់ និងមនុស្សបាប ?

តើព្រះអម្ចាស់យេស៊ូបានធ្វើដូចម្តេច ដើម្បីអោយយើងអាចចូលទៅជិតព្រះជាម្ចាស់ តាមរយៈព្រះអង្គបាន ?

ហេតុអ្វីបានជាយើងមិនអធិស្ឋានទៅកាន់ព្រលឹងខ្មោច ?

យើងអធិស្ឋានទៅកាន់*ព្រះបិតា* (ម៉ាថាយ ៦:៦-៩) ដោយនូវព្រះនាម*ព្រះបុត្រា* (យ៉ូហាន ១៤:១៣, ២០:៣១) ដោយមាន*ព្រះវិញ្ញាណដ៏វិសុទ្ធ*ជាជំនួយ (រ៉ូម ៨:២៦-២៧) ។ ព្រះយេស៊ូគ្រីស្តជាអ្នកសម្រុះសម្រួល និងស្ពានមេត្រីតែមួយគត់ ។ ព្រះ-ជាម្ចាស់ហាមយើងមិនអោយបួងសួងទៅកាន់មនុស្សស្លាប់ទេ ។ (ទុតិយកថា ១៨:១០-១១) ។

ចូរយើងប្រតិបត្តិតាមព្រះបន្ទូលនេះ (យ៉ាកុប ១:២២) ។ ការនេះជាសេចក្តីសំខាន់បំផុត ។ ព្រះជាម្ចាស់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើង ដោយធ្វើការអស្ចារ្យជាច្រើន ។ ចូរយើងធ្វើការនេះជាទម្លាប់ប្រចាំថៃចុះ ។

ដើម្បីអោយអ្នកអាចរំលឹកអំពីខ្លឹមសារនៃការសិក្សានេះឡើងវិញ សូមអាន ហើយពិចារណាពីបទគម្ពីរ ម៉ាថាយ ៦:៥-១៥ ។

☐ គូសសញ្ញា «✓» ក្នុងវង់ក្រចក នៅពេលដែលអ្នកបានអានរួចហើយ ។

គំរូបន្ថែមអំពីរបៀបអធិស្ឋាននៅក្នុងព្រះគម្ពីរ

- ទំនុកតម្កើង ៨, ៣១, ៥១, ៨៤, ១៣៩ ។
- ដានីអែល ៩:១-១៩ ។
- ព្រះអម្ចាស់ : ម៉ាថាយ ២៦:៣៦-៤២, យ៉ូហាន ១៧ ។
- ក្រុមជំនុំក្នុងកំណត់ត្រាព្រឹត្តិការ : កិច្ចការ ៤:២៣-៣១ ។
- នៅស្ថានបរមសុខ : វិវរណៈ ៥ ។

ព្រះយេស៊ូសូមអញ្ជើញអ្នកអោយអធិស្ឋាន ។ ព្រះជាម្ចាស់ចង់ប្រកបស្និទ្ធស្នាលជាមួយអ្នក ។ សេចក្តីអធិស្ឋានរបស់អ្នកមានតំលៃខ្លាំងណាស់ចំពោះព្រះអង្គ ។

ព្រះអង្គចង់អោយអ្នកថ្វាយបង្គំព្រះអង្គ ដោយវិញ្ញាណ និងដោយសេចក្តីពិត ។ ចូរស្វែងរកព្រះជាម្ចាស់ ដោយចិត្តស្រេកឃ្លាន និងមានបំណងពិតប្រាកដចង់ស្គាល់ និង ស្រឡាញ់ព្រះអង្គថែមទៀត ។ ព្រះអង្គនឹងប្រទានរង្វាន់អោយអ្នក ដោយធ្វើអោយអ្នកដឹងថា ព្រះអង្គគង់នៅជាមួយអ្នក ។

ការសំខាន់បំផុត :

បើសិនជាយើងចេះរបៀបអធិស្ឋាន ប៉ុន្តែ មិនយកពេលដើម្បីអធិស្ឋាន នោះគ្មានប្រយោជន៍ទាល់តែសោះ ។ ព្រះយេស៊ូគ្រីស្តចង់អោយយើងអធិស្ឋានដោយស្មោះអស់ពីចិត្ត ។ ព្រះអង្គមានព្រះបន្ទូលថា÷ «ចូរអធិស្ឋាន» ហេតុ នេះយើងត្រូវធ្វើតាម ។

ការអធិស្ឋានជាសេចក្តីបង្គាប់របស់ព្រះគ្រីស្ត

ពួកអ្នកជឿដែលស្រឡាញ់ព្រះជាម្ចាស់ចង់និយាយទៅរកទ្រង់ ។ នៅពេលដែលមនុស្សស្រឡាញ់គ្នា គេតែងតែចង់ប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ។ ការអធិស្ឋានធ្វើអោយយើងអាចរស់នៅដើម្បីព្រះគ្រីស្តបាន ។



ចូរយើងបង្រៀនពួកអ្នកជឿថ្មីអោយចេះអធិស្ឋាន ។ តើអ្នកបានបង្រៀនពួកអ្នកជឿថ្មីអោយចេះអធិស្ឋាន ដែរឬទេ ?

☐ បានបង្រៀនហើយ ។

☐ ខ្ញុំនឹងចាប់ផ្តើមឥឡូវនេះ ។

អ្នកជឿដែលចេះស្តាប់តាមព្រះជាម្ចាស់បានចំណាយពេលរាល់ថ្ងៃដើម្បីអធិស្ឋានតែម្នាក់ឯង ។

ព្រះអម្ចាស់បានបង្គាប់យើងថា÷ *«កាលណាអ្នករាល់គ្នាអធិស្ឋាន កុំធ្វើដូចពួកអ្នកមានពុតដែលចូលចិត្តឈរអធិស្ឋាន នៅក្នុងសាលាប្រជុំ និងនៅត្រង់ថ្នល់កែងអោយមនុស្សម្នាឃើញនោះឡើយ ។ ...រីឯអ្នកវិញ កាលណាអ្នកអធិស្ឋាន ត្រូវចូលទៅក្នុងបន្ទប់បិទទ្វារអោយជិត ហើយទូលទៅកាន់ព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីសាត់កំបាំង »* ។ (ម៉ាថាយ ៦:៥-៦)

ការអធិស្ឋាន ជាទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ដោយស្និទ្ធស្នាល

នៅពេលដែលអ្នកអធិស្ឋាន សូមចងចាំថាព្រះជាម្ចាស់ក៏គង់នៅទីនោះក្បែរអ្នកដែរ ។ អ្នកមិនអាចឃើញព្រះអង្គទេ ប៉ុន្តែ អ្នកអាចជឿជាក់ថាព្រះអង្គគង់នៅក្នុងបន្ទប់ជាមួយអ្នក ។ បើអ្នកនឹកចាំថា ព្រះអង្គកំពុងស្តាប់អ្នក នោះធ្វើអោយអ្នកអធិស្ឋានបានដោយស្រួល ។



© Project WorldReach © SEAN

តទៅទៀតទេ បើព្រះអម្ចាស់បានបង្គាញថា សំណូមពររបស់យើង
ខ្លះ មិនគាប់ព្រះហទ័យរបស់ព្រះអង្គហើយ ។

កុំស្មានថា អ្នកនឹងមានអារម្មណ៍ពិសេសនៅក្នុងចិត្តរាល់ពេលដែល
អ្នកអធិស្ឋាននោះឡើយ ។ នៅក្នុងការអធិស្ឋាន អារម្មណ៍មិនមែន
ជាការសំខាន់ទេ ។ ការអធិស្ឋានត្រូវការជំនឿ ។ យើងត្រូវទុក
ចិត្តលើព្រះជាម្ចាស់ ហើយដឹងថាព្រះអង្គស្តាប់យើង ។ កុំយកចិត្ត
ទុកដាក់ពីអារម្មណ៍របស់ខ្លួនអ្នកខ្លាំងពេក ។

យើងឆាប់បែកអារម្មណ៍ណាស់ ។ បើពេលអធិស្ឋាន យើងបែក
អារម្មណ៍ យើងត្រូវផ្ចង់ចិត្តគំនិត គិតអំពីព្រះជាម្ចាស់ ។ ត្រូវដាក់
វិន័យអោយខ្លួនឯងគិតពី «អ្វីៗដែលនៅស្ថានលើ ជាស្ថានដែល
ព្រះគ្រីស្តគង់នៅ... » (កូឡូស ៣:១-២០) ។



ហេតុអ្វីបានជាយើងត្រូវអធិស្ឋាន ?

☐ ដើម្បីអោយមនុស្សចាប់អារម្មណ៍លើយើង ។

☐ ដើម្បីអោយមនុស្សឮយើង ។

☐ ដើម្បីនិយាយទៅកាន់ព្រះជាម្ចាស់តែម្នាក់ឯង ។



ពួកអ្នកមានពុតបានអធិស្ឋាន
ដើម្បីអោយមនុស្សជាច្រើនមើល
ឃើញពួកគេ ហើយសរសើរថា
ពួកគេជាអ្នកកាន់សាសនាបាន
ខ្ជាប់ខ្ជួនល្អ ។ ពួកគេពោលពាក្យច្រំដែលឥតប្រយោជន៍ហើយ
ពោលពាក្យយ៉ាងច្រើន ដើម្បីឱ្យព្រះដែលថ្លង់របស់គេស្តាប់ឮ ។
សូមកុំធ្វើដូចគេឡើយ (ម៉ាថាយ ៦:៥-៨) ។



តាមធម្មតា តើអ្នកអធិស្ឋានម្នាក់ឯងបានយូរ នៅពេលណា ?

☐ នៅពេលព្រឹក ។

☐ ពេលរសៀល ។

☐ ពេលល្ងាច ឬ ពេលចូលដំណេក ។

យើងត្រូវអធិស្ឋាន ដោយប្រើពាក្យសាមញ្ញ

យើងត្រូវអធិស្ឋានដោយចិត្តស្លូតបូត ដូចក្មេងម្នាក់ដែលចេះស្ដាប់បង្គាប់ ។ កុំទូលទៅព្រះជាម្ចាស់ពីរបៀប ដែលព្រះអង្គត្រូវឆ្លើយតបចំពោះសេចក្ដីអធិស្ឋានរបស់យើងនោះឡើយ ។ ផ្ទុយទៅវិញ សូមទុកអោយព្រះអង្គជាអ្នកសំរេចចុះ ។

ចំលើយប្រហែលជាមិនដូចជាការដែលយើងបានសង្ឃឹមទុក ឬ ប្រហែលជាយើងមិនបានទទួលភ្លាមៗនោះទេ ។ ព្រះជាម្ចាស់ជាព្រះអាទិកររបស់យើង ហើយព្រះអង្គស្គាល់ស្ថានភាពរបស់យើងប្រសើរជាងយើងទៅទៀត ។ ព្រះអង្គនឹងឆ្លើយតបទៅតាមរបៀបល្អបំផុត ។

ប្រសិនបើព្រះជាម្ចាស់មិនឆ្លើយតបចំពោះសំណូមពរពិសេសណាមួយ ប៉ុន្តែ អ្នកជឿថាសំណូមពរនេះជាព្រះហឫទ័យព្រះអង្គ សូមអត់ធ្មត់អធិស្ឋានបន្តទៀត ។ ព្រះយេស៊ូគ្រីស្ដបានបង្គាប់អោយយើងព្យាយាមអធិស្ឋាន (លូកា ១៨:១-៨) ។ ព្រះអង្គប្រហែលជាឆ្លើយតបចំពោះសេចក្ដីអធិស្ឋានរបស់អ្នក នៅពេលក្រោយ ឬ ប្រទានឱ្យអ្នកនូវអ្វីផ្សេងដែលប្រសើរជាងនេះ ។ ប្រសិនជាព្រះអង្គមិនឆ្លើយតបទេនោះ អ្វីដែលអ្នកទូលសូមនោះ ប្រហែលជាមិនស្របតាមព្រះហឫទ័យទ្រង់ទេ ។ យើងមិនត្រូវទូលសូមព្រះអង្គ

- ការទូលសូមអោយព្រះអង្គប្រទានអ្វីមួយដោយចិត្តអំនួត ឬ គិតតែពីប្រយោជន៍ផ្ទាល់ខ្លួន (យ៉ាកុប ៤:៣, ១ យ៉ូហាន ៥:១៤-១៥) ។
- ការទូលសូមដោយគ្មានជំនឿ ឬ ដោយមានជំនឿតិចចំពោះព្រះជាម្ចាស់ ឬសង្ស័យ (ម៉ាកុស ១១:២៣-២៤, យ៉ាកុប ១:៦-៨) ។
- ការមិនអោយកិត្តិយស និងមិនគោរពចំពោះគូស្រករ (១ ពេត្រុស ៣:៧) ។
- ការមានទំនាស់នឹងមនុស្សឯទៀត (ម៉ាថាយ ៥:២៣-២៤) ។

នៅពេលដែលយើងដឹងថា យើងបានប្រព្រឹត្តខុស យើងត្រូវលន់តួសារភាពអំពើបាបនោះភ្លាម។ នៅពេលដែលយើងលន់តួសារភាពអំពើបាបរបស់យើង ហើយពិតជាបានកែប្រែចិត្តមែន ព្រះជាម្ចាស់នឹងអត់ទោសអោយយើងជាមិនខាន (១ យ៉ូហាន ១:៩) ។

យើងក៏អរព្រះគុណព្រះជាម្ចាស់ មុនបរិភោគអាហារដែរ ។



យើងត្រូវអធិស្ឋាន ដោយប្រើ :

☐ ពាក្យពេចន៍ផ្ទាល់របស់យើង ។

☐ ពាក្យអធិស្ឋានដែលបានទន្ទេញចាំមាត់ ។

ការដែលយើងអធិស្ឋានតាមរបៀបកូននិយាយទៅកាន់ឪពុកជាការល្អបំផុត ។

យើងត្រូវអធិស្ឋានជាមួយក្រុមគ្រួសាររបស់យើងជារៀងរាល់ថ្ងៃ ។ ចូរយើងបង្រៀនកូនៗរបស់យើងអោយចេះអធិស្ឋានផងដែរ ។ ហេតុអ្វីបានជាយើងត្រូវបង្រៀនកូនៗឱ្យអធិស្ឋានតាមរបៀបនេះ ?

_____

_____

_____

_____

ការអធិស្ឋានមានគោលដៅច្រើនយ៉ាង

«សេចក្តីអធិស្ឋានរបស់ព្រះអម្ចាស់ »ជាគំរូសំរាប់យើង (ម៉ាថាយ ៦:៩-១៣) ។ ព្រះអម្ចាស់យេស៊ូបង្ហាញយើងពីសេចក្តី ដែលយើងត្រូវអធិស្ឋាន :

ព្រះជាម្ចាស់នឹងឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើង បើយើងស្តាប់បង្គាប់ព្រះអង្គ

យើងត្រូវចេះបន្ទាបខ្លួននៅចំពោះព្រះជាម្ចាស់ និងមានបំណងខ្លាំងក្លាចង់ស្តាប់បង្គាប់ព្រះអង្គ ដើម្បីអោយព្រះអង្គឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់យើង (យ៉ូហាន ១៥:៧, ១ យ៉ូហាន ៣:២១-២២) ។ ព្រះអង្គចង់អោយយើងប្រតិបត្តិតាមសេចក្តីដែលព្រះគម្ពីរបានចែង ។ ការមិនស្តាប់បង្គាប់ព្រះអង្គ គឺជាអំពើបាប និងអាចធ្វើអោយការអធិស្ឋានមិនបានទទួលចំលើយ (១ ពេត្រុស ៣:១២) ។

អំពើបាបប្រាំយ៉ាង ដែលធ្វើអោយព្រះជាម្ចាស់មិនឆ្លើយតបចំពោះការអធិស្ឋានរបស់យើង :

- មិនចង់អត់ទោសអោយនរណាម្នាក់ ឬ ក៏មិនខិតខំទៅសម្រុះសម្រួលអោយជានាជាមួយនរណាម្នាក់ ទោះជាយើងដឹងក្នុងចិត្តថា ព្រះជាម្ចាស់ចង់អោយយើងធ្វើជាអ្នកកសាងសន្តិភាពក៏ដោយ (ម៉ាថាយ ៥:២៣-២៤, ម៉ាកុស ១១:២៥) ។

- យើងត្រូវ «អធិស្ឋានឥតឈប់ឈរ» (អេភេសូ ៦:១៨) ។ ព្រះអម្ចាស់ចង់ឱ្យយើងមានទំនាក់ទំនងមេត្រីភាពជាមួយនឹងព្រះអង្គរាល់ថ្ងៃ ។ សូមនិយាយទៅកាន់ព្រះជាម្ចាស់ឱ្យបានច្រើនបំផុត ។ ទោះជាដៃរបស់អ្នកកំពុងជាប់រវល់ ក៏សូមថ្វាយចិត្តគំនិតរបស់អ្នកដល់ព្រះជាម្ចាស់ ដោយអធិស្ឋានដែរ ។ សូមសាកល្បងធ្វើតាមសេចក្តីនេះ នោះអ្នកនឹងទទួលលទ្ធផលដែលធ្វើអោយអ្នកសប្បាយចិត្ត ! ។

« ចូរព្យាយាមអធិស្ឋាន ហើយប្រុងស្មារតីក្នុងការអធិស្ឋាននេះទាំងអរព្រះគុណព្រះជាម្ចាស់ផង » (កូឡូស ៤:២) ។

តើអ្នកចង់ផ្លាស់ប្តូររបៀបអធិស្ឋានរបស់អ្នកដូចម្តេចខ្លះ ?

១- សរសើរតម្កើងព្រះជាម្ចាស់ ។

«ឱព្រះបិតានៃយើងខ្ញុំ ដែលគង់នៅស្ថានបរមសុខអើយ ! សូមអោយព្រះនាមព្រះអង្គបានវិសុទ្ធ » ។ យើងចូលមកឯវត្តមានរបស់ព្រះអង្គ ដោយសរសើរ និង អរព្រះគុណព្រះជាម្ចាស់ ។



«កុំស្រវឹងស្រា ព្រោះស្រាបណ្តាលអោយថោកទាប ផ្ទុយទៅវិញ ត្រូវអោយបានពោរពេញដោយព្រះវិញ្ញាណ ។ ចូរនិយាយគ្នាទៅវិញទៅមក ដោយប្រើទំនុកតម្កើង បទសរសើរព្រះជាម្ចាស់ និងបទចំរៀងមកពីព្រះវិញ្ញាណ ។ ចូរច្រៀង និង លើកតម្កើងព្រះអម្ចាស់អោយអស់ពីចិត្ត ។ ត្រូវអរព្រះគុណព្រះជាម្ចាស់ជាព្រះបិតាគ្រប់ពេលវេលា និងគ្រប់កិច្ចការក្នុងព្រះនាមព្រះយេស៊ូគ្រីស្តជាព្រះអម្ចាស់នៃយើង»។

(អេភេសូ ៥:១៨-២០)

នាងម៉ារីជាមាតារបស់ព្រះយេស៊ូគ្រីស្ត សរសើរតម្កើងព្រះជាម្ចាស់ ដោយពាក្យទាំងនេះ :



«ព្រលឹងខ្ញុំសូមលើកតម្កើងព្រះ-អម្ចាស់ ខ្ញុំមានចិត្តអំណរជាខ្លាំង ព្រោះព្រះជាម្ចាស់ជាព្រះសង្គ្រោះរបស់ខ្ញុំ ព្រះអង្គទតមើលមកខ្ញុំ ដែលជាអ្នកបំរើដ៏ទន់ទាបរបស់ព្រះអង្គ ។ អំណើះតទៅមនុស្សគ្រប់ជំនាន់នឹងពោលថា ខ្ញុំជាអ្នកមានសុភមង្គលពិតមែន ។ ព្រះដ៏មានឫទ្ធានុភាពបានសំដែងការប្រសើរអស្ចារ្យចំពោះរូបខ្ញុំ ។ ព្រះនាមរបស់ព្រះអង្គពិតជាវិសុទ្ធមែន ! ទ្រង់មានព្រះហឫទ័យមេត្តាករុណាដល់អស់អ្នក ដែលកោតខ្លាចព្រះអង្គនៅគ្រប់ជំនាន់តរៀងទៅ » ។

(លូកា ១:៤៦-៥០)

ការអធិស្ឋាននៅក្នុងឱកាសផ្សេងៗទៀត

- យើងអាចអរព្រះគុណ មុននឹងបរិភោគអាហារគ្រប់ពេល ។
- យើងត្រូវជួបគ្នាជាមួយក្រុមគ្រួសាររបស់យើង ដើម្បីអធិស្ឋាន មួយថ្ងៃម្តង ។ នៅពេលជាមួយគ្នានោះ យើងអាចច្រៀងសរសើរតម្កើងព្រះជាម្ចាស់ និងអានព្រះគម្ពីរផងដែរ ។
- ការអធិស្ឋានមុនពេលបរិភោគអាហារ និងការអធិស្ឋានជាមួយក្រុមគ្រួសារ ត្រូវឱ្យស្រួលជាង និងខ្លីជាងការអធិស្ឋានតែម្នាក់ឯង ។ ចូរយើងកុំធ្វើឱ្យកូនៗរបស់យើងធុញទ្រាន់ ។
- យើងត្រូវអធិស្ឋាន មុនពេលយើងចេញទៅផ្សព្វផ្សាយដំណឹងល្អអំពីព្រះយេស៊ូគ្រីស្តជាមួយគ្រីស្តជនឯទៀត ។
- នៅពេលដែលអ្នកចេញទៅផ្សាយដំណឹងល្អ ហើយពេលដែលមិត្តភ័ក្តិរបស់អ្នកកំពុងនិយាយទៅកាន់មនុស្សណាម្នាក់ សូមអធិស្ឋានក្នុងចិត្ត ។

អំពីការតមអាហារ :

«ការតមអាហារ» (ការមិនបរិភោគអាហារ) មិនមានចែងនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ជាសេចក្តីបង្គាប់ទេ ។ ព្រះយេស៊ូ និងពួកសាវ័កបានតមអាហាររួមជាមួយការអធិស្ឋាន ដើម្បីរៀបចំធ្វើកិច្ចការពិសេស (ម៉ាថាយ ៤:១-១១, កិច្ចការ ១៣:១-៣) ។ ក្រៅពីតមអាហារ គ្រីស្តជនខ្លះយល់ថា បើផ្អាកកិច្ចការផ្សេងៗ ដូចជា ការកំសាន្ត ការលេងកីឡា ការសំរាន្ត និងការមើលទូទស្សន៍ ដើម្បីអធិស្ឋាន និងរិះគិតពិចារណាអំពីព្រះជាម្ចាស់ និងព្រះហឫទ័យរបស់ព្រះអង្គវិញ ជាការមានប្រយោជន៍ណាស់ ។ ព្រះយេស៊ូបានប្រៀនប្រដៅ មិនអោយយើងតមអាហារ ដើម្បីមូលហេតុខុសឆ្គងទេ ។ ព្រះអង្គស្តីបន្ទោសពួកគណៈផារីស៊ី ដែលតមអាហារ គ្រាន់តែដើម្បីអោយគេមើលឃើញថាខ្លួនវិសុទ្ធប៉ុណ្ណោះ ។ ពួកហិណ្ឌូ និង ពួកមូស្លីមខិតខំតមអាហារ ដើម្បីសន្សំកុសលដោយធ្វើវិធីសាសនាតាមទំលាប់ ។

២- ពង្រីកព្រះរាជ្យរបស់ព្រះជាម្ចាស់នៅលើផែនដី ។

«...សូមអោយព្រះរាជ្យរបស់ព្រះអង្គបានមកដល់ សូមអោយព្រះហឫទ័យរបស់ព្រះអង្គបានសំរេចនៅលើផែនដី ដូចនៅស្ថានបរមសុខដែរ...» ។



«ជាបឋម ខ្ញុំសូមផ្តែផ្តាំអោយគេទូលសូមព្រះជាម្ចាស់អធិស្ឋាន និងអង្វរព្រះអង្គទាំងអរព្រះគុណសំរាប់មនុស្សទាំងអស់ផង ។ ត្រូវទូលអង្វរសំរាប់ស្តេច និងអ្នកកាន់អំណាចគ្រប់ៗរូប ដើម្បីអោយយើងរស់នៅបានសុខក្សេមក្សាន្ត គ្មានចលាចល ទាំងគោរពប្រណិប័តន៍ព្រះជាម្ចាស់ អស់ពីចិត្ត និងមានជីវិតថ្លៃថ្នូរ ។ នេះហើយជាការល្អ និងគាប់ព្រះ-ហឫទ័យព្រះជាម្ចាស់ ជាព្រះសង្គ្រោះរបស់យើង ដែលទ្រង់សព្វព្រះហឫទ័យឱ្យមនុស្សទាំងអស់បានទទួលការសង្គ្រោះ និងស្គាល់សេចក្តីពិតយ៉ាងច្បាស់» ។

(១ ធីម៉ូថេ ២:១-៤)

តាមរយៈសេចក្តីអធិស្ឋានរបស់យើង ព្រះជាម្ចាស់ពង្រីកព្រះរាជ្យរបស់ព្រះអង្គ និងធ្វើអោយព្រះបំណងរបស់ព្រះអង្គបានសំរេចនៅលើផែនដីនេះ នៅក្នុង :

- ជីវិតផ្ទាល់របស់យើង
- ក្រុមគ្រួសាររបស់យើង
- ក្រុមជំនុំ និងកិច្ចការបំរើរបស់ក្រុមជំនុំ
- ការធ្វើអោយអ្នកបាត់បង់ក្នុងអំពើបាប ថ្វាយខ្លួន ។
- ការប្រោសអ្នកឈឺអោយជា
- មុខរបររបស់អ្នក
- រដ្ឋាភិបាល ។

ដូច្នេះ ការអធិស្ឋានមានប្រយោជន៍ធំអស្ចារ្យណាស់ ! ។

ការអធិស្ឋានអាចកាន់តែមានប្រសិទ្ធិភាព បើមានការតមអាហារ និងមានការអធិស្ឋាន រយៈពេលយូរ ឬពេញមួយយប់

គ្មានសេចក្តីបង្គាប់ដែលនិយាយអំពីការតមអាហារ ឬ «ការអធិស្ឋានពេញមួយយប់ »នោះទេ ។ ប៉ុន្តែ នៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មី ការតមអាហារគឺជាសកម្មភាពធម្មតាសំរាប់គ្រីស្ត-បរិស័ទ ។ ព្រះយេស៊ូផ្ទាល់បានចាំយាមអធិស្ឋានពេញមួយយប់ (លូកា ៦:១២) ។ ព្រះអម្ចាស់ក៏បានតមដែរ មុនពេលព្រះអង្គចាប់ផ្តើមធ្វើកិច្ចការបំរើ (ម៉ាថាយ ៤:១-២) ។

នៅពេលដែលអ្នកតម ឬ ធ្វើការអធិស្ឋានចាំយាម បើអ្នកប្រាប់មនុស្សច្រើនអោយដឹងដើម្បីអួតខ្លួន នោះអ្នកជាមនុស្សមានពុតត្បុតហើយ ។

ព្រះអម្ចាស់យេស៊ូបានមានព្រះបន្ទូលថា « *រីឯអ្នកវិញ កាលណាអ្នកតមអាហារ ត្រូវលាបទឹកអប់លើក្បាល ហើយលប់មុខផង ។ កុំអោយមនុស្សម្នាឃើញថាអ្នកតមឡើយ គឺអោយតែព្រះបិតារបស់អ្នក ដែលគង់នៅក្នុងទីស្ងាត់កំបាំងទតឃើញប៉ុណ្ណោះ...* » ។

(ម៉ាថាយ ៦:១៧-១៨)

ហប្ញទ័យរបស់ព្រះអង្គ ធ្វើអោយអ្នកដឹងកាន់តែច្បាស់អំពីបំណង ព្រះហប្ញទ័យរបស់ព្រះអង្គសំរាប់អ្នក បង្ហាញអ្នកអំពីរបៀបបំរើព្រះអង្គល្អបំផុត បង្ហាញអ្នកពីមនុស្សដែលអ្នកត្រូវទៅផ្សព្វផ្សាយដំណឹងល្អ បង្ហាញអ្នកពីអ្នកណាម្នាក់ដែលកំពុងខ្វះខាត និងពីរបៀបជួយអ្នកនោះ ។

តាមធម្មតា អ្នកឮព្រះជាម្ចាស់មានបន្ទូលនៅក្នុងចិត្តច្រើនជាងនៅក្នុងត្រចៀករបស់អ្នក ។

តើយើងគួរទុកចិត្តអ្វីជាង ?

☐ សុបិន ។

☐ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ។



៣- ទូលសូមអំពីសេចក្តីត្រូវការរបស់យើង ។

«សូមប្រទានអាហារដែលយើងខ្ញុំត្រូវការនៅថ្ងៃនេះ » ។



«មកទល់ពេលនេះ អ្នករាល់គ្នាពុំទាន់បានទូលសូមអ្វីក្នុងនាមខ្ញុំទេ ចូរទូលសូមទៅ អ្នករាល់គ្នានឹងបានទទួល ហើយអ្នករាល់គ្នានឹងមានអំណរពេញលក្ខណៈ » ។

(យ៉ូហាន ១៦:២៤)

ត្រូវអធិស្ឋានទូលសូមអ្វីមួយឱ្យច្បាស់លាស់ ។ ព្រះជាម្ចាស់នឹងផ្តល់អោយយើងគ្រប់អ្វីៗទាំងអស់ ដែលយើងត្រូវការ ហើយព្រះអង្គថែមទាំងចំរុងចំរើនយើង ដើម្បីអោយយើងអាចជួយដល់អ្នកដទៃទៀតផង ។



ការអធិស្ឋាន និង ការគិតពិចារណាពីព្រះគម្ពីរ ជាការសន្ទនារបស់យើងជាមួយព្រះជាម្ចាស់

ព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់យើង តាមរយៈព្រះគម្ពីរ ។ ព្រះគម្ពីរគ្រប់គ្រាន់សំរាប់បង្រៀនពីសេចក្តីគ្រប់យ៉ាង (២ ធីម៉ូថេ ៣:១៦-១៧) ។ យើងមិនត្រូវបន្ថែមបន្ថយសេចក្តីអ្វី នៅក្នុងព្រះបន្ទូលព្រះជាម្ចាស់ទេ (វិវរណៈ ២២:១៨-១៩) ។

ព្រះជាម្ចាស់អាចមានព្រះបន្ទូលតាមរយៈសុបិន ទំនាយ ឬក្នុងចិត្តគំនិតរបស់យើងផ្ទាល់តែម្តង ។ ប៉ុន្តែ សេចក្តីទាំងអស់នេះ ត្រូវស្របទៅតាមសេចក្តីដែលព្រះគម្ពីរបានចែង ។ ព្រះជាម្ចាស់មិនធ្វើអ្វីដែលផ្ទុយពីព្រះបន្ទូលរបស់ព្រះអង្គឡើយ ។

នៅពេលដែលអ្នកនិយាយទៅកាន់ព្រះជាម្ចាស់ចប់ហើយ សូមនៅផ្ចង់ចិត្តគំនិតគិតអំពីព្រះអង្គអោយបានយូរបន្តិចសិន ។

សូមផ្ចង់គំនិតរបស់អ្នកទៅរកព្រះអង្គ ហើយគិតពិចារណាអំពីព្រះអង្គ និងអំពីសេចក្តីដែលព្រះអង្គមានព្រះបន្ទូលនៅក្នុងព្រះគម្ពីរ ។ បន្ទាប់មក ព្រះអង្គអាចមានបន្ទូលមកកាន់អ្នកដូចជារំលឹកអ្នកអំពីអ្វីៗនៅក្នុងជីវិតរបស់អ្នក ដែលមិនគាប់ព្រះ-

© Project WorldReach © SEAN

អ្នកខ្លះអធិស្ឋាន ក្រាបចុះឱនមុខដល់ដី
ដើម្បីទូលអង្វរពីរឿង ដែលសំខាន់ៗ
(ជំរឿនប្រជាជន ២១:៦) ។



ព្រះជាម្ចាស់មិនទតមើលពីស្ថានភាពរូបកាយ
របស់យើងទេ តែព្រះអង្គទតមើលទឹក
ចិត្តរបស់យើងទៅវិញ ។

តើមួយណាសំខាន់ជាង ?

☐ ស្ថានភាពនៃរូបកាយ ។

☐ ចិត្តដែលគោរពកោតខ្លាច ។

ពេលអធិស្ឋានជាមួយបងប្អូនឯទៀត ត្រូវអោយមានសណ្តាប់ធ្នាប់

ព្យាការីក្លែងក្លាយរបស់ព្រះបាលបានស្រែកខ្លាំងៗ ដោយច្រួល
ច្របល់ (១ ពង្សាវតារក្សត្រ ១៨:២៥-២៩) ។

ព្រះជាម្ចាស់បានបង្គាប់អោយយើងអធិស្ឋានរួមគ្នា ដោយមាន
សណ្តាប់ធ្នាប់ (១ កូរិនថូស ១៤:១៤-១៧, ៣១-៣៣, ៤០)។

ប៉ុន្តែ ជួនកាលព្រះជាម្ចាស់មិនឆ្លើយតបទេ ។
ហេតុអ្វី ? តើខ្ញុំបានធ្វើអ្វីខុសឬ ?



ជួនកាល ដូចជាលោកយ៉ូប ឬ ព្រះយេស៊ូនៅក្នុង
សួនកេតសេម៉ានីដំបូងដែរ គឺយើងមិនបានធ្វើអ្វីខុសទេ
ប៉ុន្តែ ព្រះជាម្ចាស់មានហេតុផលផ្ទាល់របស់ព្រះអង្គ
ដែលមិនប្រទានអោយតាមចិត្តរបស់យើង ។ មួយ
វិញទៀត ព្រោះតែមូលហេតុដែលមានចែងក្នុងយ៉ាកុប
៤:៣ “បងប្អូនទូលសុំដែរ តែឥតបានទទួល ព្រោះបង
ប្អូនទូលសុំដោយបំណងអាក្រក់ គឺបងប្អូនចង់បានសំរាប់
តែបំពេញចិត្តស្រើបស្រាលរបស់ខ្លួនប៉ុណ្ណោះ ” ។



ការអធិស្ឋានត្រូវធ្វើឡើង ដោយចិត្តស្មោះត្រង់

«*ចូរអធិស្ឋានឥតឈប់ឈរ*» (១ ថែស្សាឡូនិក ៥:១៧)។ ចូរយកចិត្តទុកដាក់ត្រៀមខ្លួនអធិស្ឋាន នៅគ្រប់ពេលដែលព្រះវិញ្ញាណដ៏វិសុទ្ធដាស់តឿនយើង ។ ស្ថានភាពរបស់រូបកាយអាចបង្ហាញពីទឹកចិត្តរបស់យើង ។

មនុស្សជាច្រើនបានអធិស្ឋានដោយបិទភ្នែកដើម្បីចៀសវាងកុំឱ្យមានការរំខាន និងអាចផ្តង់គំនិតអោយគិតតែពីព្រះជាម្ចាស់ ។



នៅក្នុងព្រះគម្ពីរ មនុស្សខ្លះបានលុតជង្គង់អោនក្បាលដល់ដី ដើម្បីអធិស្ឋានថ្វាយបង្គំព្រះ-ជាម្ចាស់ (កំណើតពិភពលោក ២៤:២៦) ។



ស្តេចសាឡូម៉ូនបានឈរអធិស្ឋាន នៅពេលដែលទ្រង់អធិស្ឋានថ្វាយព្រះវិហារ (១ ពង្សាវតារក្សត្រ ៨:២២-២៣) ។



អ្នកខ្លះលុតជង្គង់អធិស្ឋាន ដើម្បីបន្ទាបខ្លួន (លូកា ២២:៤១) ។

៥- ទូលសូមឱ្យព្រះជាម្ចាស់ការពារយើងខាងព្រលឹងវិញ្ញាណ ។



«សូមកុំបណ្តោយអោយយើងខ្ញុំចាញ់ការល្បួងឡើយ តែសូមរំដោះយើងខ្ញុំអោយរួចពីមារកំណាច» ។

យើងទូលសូមអោយព្រះជាម្ចាស់ជួយការពារយើង កុំអោយធ្លាក់ក្នុងសេចក្តីល្បួង និងការពារយើងពីសត្រូវរបស់យើង គឺមារសាតាំង ។ ចូរយើងពាក់គ្រឿងសស្ត្រាវុធរបស់ព្រះជាម្ចាស់ដោយអធិស្ឋាន មុននឹងចេញទៅធ្វើការប្រយុទ្ធប្រចាំថ្ងៃរបស់យើង (អេភេសូ ៦:១០-២០) ។

៦- បញ្ចប់ដោយថ្វាយសិរីរុងរឿងដល់ព្រះជាម្ចាស់ ។

«ដ្បិតព្រះអង្គគ្រងរាជ្យ ទ្រង់មានឫទ្ធានុភាព និងសិរីរុងរឿងអស់កល្បជាអង្វែងតរៀងទៅ អាម៉ែន ! » ។

យើងថ្វាយសិរីរុងរឿងចំពោះព្រះជាម្ចាស់ ពីព្រោះព្រះអង្គជាអ្នកមានជ័យជំនះ ។

ចូរយើងទូលសូមដោយបន្ទាបខ្លួន ស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ។ ចូរយើងកុំបង្គាប់ព្រះជាម្ចាស់អោយធ្វើនេះធ្វើនោះឡើយ ព្រោះព្រះអង្គជាអ្នកបង្គាប់យើងទៅវិញទេ ។ ព្រះយេស៊ូបានប្រទានឧទាហរណ៍អំពីរបៀបអធិស្ឋាន ដោយបន្ទាបខ្លួន នៅក្នុងសួនច្បារកេតសេម៉ានី (ម៉ាថាយ ២៦:៣៩) ថា :

ឱ ព្រះបិតាអើយ ! ប្រសិនបើបាន សូមអោយពែងនៃទុក្ខលំបាកនេះ ចេញឆ្ងាយពីទូលបង្គំទៅ ! ប៉ុន្តែ សូមកុំធ្វើតាមបំណងទូលបង្គំឡើយ គឺសូមឱ្យបានសំរេចតាមព្រះហឫទ័យរបស់ព្រះអង្គវិញ ។



ហេតុអ្វីបានជាការទូលសូមដោយទាមទារអ្វីៗពីព្រះជាម្ចាស់ ជាការមិនសមគួរ ?

_____

_____

_____

_____

_____

_____

៤- ទូលសូមព្រះជាម្ចាស់អត់ទោសអោយអ្នក (ចូរអ្នកអត់ទោសអោយអ្នកដទៃផង) ។

« សូមអត់ទោសអោយយើងខ្ញុំដូចយើងខ្ញុំអត់ទោសអោយអស់អ្នកដែលបានប្រព្រឹត្តខុសនឹងយើងខ្ញុំ » ។



« ប៉ុន្តែ បើយើងទទួលសារភាពអំពើបាបរបស់យើង នោះព្រះជាម្ចាស់ដែលមានព្រះហឫទ័យស្មោះស្ម័គ្រ និងសុចរិត ទ្រង់នឹងអត់ទោសយើងអោយរួចពីបាប ព្រមទាំងជំរះយើងឱ្យបានបរិសុទ្ធ រួចពីគ្រប់អំពើទុច្ចរិតទាំងអស់ផង ។ ប្រសិនបើយើងពោលថា យើងគ្មានបាបសោះ នោះដូចជាយើងចោទថាព្រះជាម្ចាស់កុហកទៅវិញ ហើយព្រះបន្ទូលរបស់ព្រះអង្គមិនស្ថិតនៅក្នុងខ្លួនយើងទេ » ។

(១ យ៉ូហាន ១:៩-១០)

យើងមិនគ្រាន់តែទូលសូមអោយព្រះជាម្ចាស់អត់ទោសអោយយើងប៉ុណ្ណោះទេ តែយើងក៏ត្រូវអត់ទោសអោយអស់អ្នកដែលបានប្រព្រឹត្តខុសមកលើយើង ដោយចិត្តស្មោះត្រង់ផងដែរ ។ យើងត្រូវទូលសូមអោយព្រះជាម្ចាស់លើកលែងទោសអោយពួកគេដែរ ។ ពេលខ្លះ យើងត្រូវទូលសូមឱ្យព្រះជាម្ចាស់ធ្វើអោយយើងមានចិត្តទន់ ដើម្បីឱ្យយើងអាចអត់ទោសអោយមនុស្សឯទៀត ។

© Project WorldReach © SEAN